# សេចក្តីណែនាំអំពីការគ្រប់គ្រងការប៉ះពាល់នៃជំងឺ COVID-19 សម្រាប់កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ

**បច្ចុប្បន្នភាពថ្មីៗ** - (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)
**10/7/2021**

- បានបន្ថែមជម្រើសនៃការធ្វើចត្តាឡីស័ករយៈពេលខ្លីសម្រាប់អ្នកដែលបានប៉ះពាល់នឹងមេរោគ ហើយដែលនៅតែមិនមានចេញរោគសញ្ញា និងបានប្រមូលសំណាកនៅថ្ងៃទី 5 ឬក្រោយពីនេះ បន្ទាប់ពីកាលបរិច្ឆេទនៃការប៉ះពាល់ចុងក្រោយ និងធ្វើតេស្តទទួលលទ្ធផលអវិជ្ជមាន។
- បានបញ្ជាក់យ៉ាងច្បាស់ថា សមាជិកនានានៅក្នុងក្រុមតែមួយជាមួយនឹងករណីដែលមានជំងឺច្បាស់លាស់ គឺតម្រូវឱ្យធ្វើតេស្តជារៀងរាល់សប្តាហ៍រយៈពេល 2 សប្តាហ៍គិតចាប់ពីថ្ងៃចុងក្រោយដែលករណីនោះមានវត្តមានក្នុងក្រុមខណៈពេលដែលអាចចម្លងមេរោគបាន ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការ ឬប៉ះពាល់នឹងមេរោគឡើយ។
- បានបន្ថែមទៀតថា ក្រុម ឬពួកកីឡាករនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការផ្ទុះជំងឺឡើងយ៉ាងសកម្ម ប្រហែលជាអាចត្រូវបានតម្រូវឱ្យផ្អាកសកម្មភាពនានារហូតដល់មានការជូនដំណឹងបន្ថែមពី DPH។
- បានបញ្ជាក់យ៉ាងច្បាស់ថា ការដាក់បញ្ជូននូវលទ្ធផលវិជ្ជមានមិនពិត នឹងមិនទទួលយកទេ សម្រាប់កម្មវិធីកីឡាយុវជនដែលកំពុងមានការផ្ទុះជំងឺឡើងយ៉ាងសកម្មនោះទេ។
- រៀបចំមាតិកាឡើងវិញសម្រាប់ភាពងាយស្រួលក្នុងការអាន និងការយល់។

ការឆ្លើយតបសុខភាពសាធារណៈដែលមានគោលដៅដើម្បីគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 នៅកម្រិតសហគមន៍ អាចជួយបង្កើនឥទ្ធិពលនៃការឆ្លើយតបនឹងជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (DPH) ឱ្យខ្លាំងជាងគេ។

កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ (Organized Youth Sports Programs) គឺជាដៃគូសហគមន៍ដែលគួរឱ្យទុកចិត្ត ហើយដែលអាចជួយដល់ DPH ធ្វើឱ្យឥទ្ធិពលនៃការឆ្លើយតបរបស់សុខភាពសាធារណៈប្រសើរឡើងនិងទាន់ពេលវេលា តាមរយៈការផ្តួចផ្តើមជាបន្ទាន់នៃផែនការគ្រប់គ្រងការផលប៉ះពាល់ (EMP) សម្រាប់ជំងឺ COVID-19។ ការអនុវត្តភ្លាមៗនៃផែនការ EMP នៅពេលដែលបានកំណត់អត្តសញ្ញាណករណីនៃជំងឺ COVID-19 មួយ អាចធ្វើឱ្យសមត្ថភាពក្នុងការគ្រប់គ្រងការរីករាលដាលនៃការឆ្លងបានលឿនជាងមុន និងបង្ការការផ្ទុះឡើងនៃជំងឺ ក្នុងកម្មវិធីកីឡាកម្សាន្ត។

ជំហានសម្រាប់គ្រប់គ្រងការប៉ះពាល់ជំងឺ COVID-19 ចំនួន 1 2 និង 3 ករណីឡើងទៅនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវមួយ ត្រូវបានពិពណ៌នាដូចខាងក្រោម និងបានសង្ខេបនៅក្នុងឧបសម្ព័ន្ធ A ។ ដោយសារតែកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវនានា មានកម្រិតធនធានខុសៗគ្នាសម្រាប់ការគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 យ៉ាងហោចណាស់ត្រូវតែរាប់បញ្ចូលជំហានដែល *ចាំបាច់* ទៅក្នុងផែនការ EMP។ ជំហានដែល *បានណែនាំ* បូកបញ្ចូលកត្តាដែលអាចជ្រើសរើសបានសម្រាប់ការគ្រប់គ្រងការប៉ះពាល់ ប្រសិនបើមានធនធានគ្រប់គ្រាន់។

ចូរកត់សម្គាល់ថា សេចក្តីណែនាំអំពីការគ្រប់គ្រងការប៉ះពាល់នេះអនុវត្តចំពោះសម្ព័ន្ធកីឡាកម្សាន្តដែលមានការរៀបចំត្រឹមត្រូវទាំងឡាយ ក្លឹបកីឡា កីឡាដែលត្រូវធ្វើដំណើរ ព្រឹត្តិការណ៍/ការជួបជុំ/ការប្រកួតប្រជែងកីឡានានា និងកីឡាដែលបានឧបត្ថម្ភដោយសាលារៀនឯកជននិងសាធារណៈ ដែលបម្រើការជូនសិស្សនៅក្នុងសាលារៀនកម្រិត TK12។ ការណែនាំនេះបំពេញបន្ថែមទៅលើ ពិធីការសម្រាប់ក្រុមកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ដែលផ្តល់នូវសេចក្តីសង្ខេបនៃតម្រូវការ និងគំរូអនុវត្តល្អៗបំផុតនៅក្នុងការទីតាំងនេះ។ **សេចក្តីណែនាំនេះមិនអនុវត្តចំពោះក្រុមកីឡាកម្រិតមហាវិទ្យាល័យ ឬអាជីព ឬព្រឹត្តិការណ៍ក្នុងសហគមន៍ផ្សេងៗ ដូចជាកីឡាការរត់ម៉ារ៉ាតុង ពាក់កណ្តាលម៉ារ៉ាតុង និងការរត់ប្រណាំង (endurance races) ឡើយ។**

ហានិភ័យនៃការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងកម្មវិធីកីឡាសម្រាប់យុវជនអាចផ្លាស់ប្តូរបានដោយកត្តាផ្សេងៗដូចខាងក្រោម៖

- នៅពេលមានបុគ្គលជាច្រើនបានចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺ COVID-19 ពេញលេញ ហានិភ័យមាន**ការថយចុះ**។
- ក្នុងករណីមិនមានការចាក់ថ្នាំបង្ការជំងឺ COVID-19 ហានិភ័យមាន**ការកើនឡើង**ដោយសារ៖ (1) ប្រភេទកីឡាដែលមានកម្រិតនៃការប៉ះពាល់ជិតស្និទ្ធខ្លាំងរវាងអ្នកចូលរួម (ជាពិសេសការប៉ះពាល់ទល់មុខគ្នា សម្រាប់ប្រភេទ

កីឡាដែលនៅខាងក្នុងអគារ) (2) ប្រភេទកីឡាដែលមានការប៉ះពាល់ជិតស្និទ្ធញឹកញាប់ និងរយៈពេលយូរ (3) ប្រភេទកីឡាដែលមានការប៉ះពាល់ច្រើន ហើយដោយបញ្ចេញកំលាំងខ្លាំង ដែលបង្កើនកម្រិតនៃការដកដង្ហើម និងបរិមាណខ្យល់ចូលនិងចេញរាល់ការដកដង្ហើមម្តងៗ។

នៅក្នុងពិធីការខាងក្រោមពាក្យថា "ក្រុមគ្រួសារ" គឺមានន័យថា "មនុស្សណាដែលរស់នៅជាមួយគ្នាក្រោមដំបូលតែមួយ" ហើយមិនត្រូវរាប់បញ្ចូលទាំងស្ថានភាពរស់នៅជាក្រុមរួមស្ថាប័ន ដូចជាសយនដ្ឋាន (dormitories) សមាគមបុរស (fraternities) សមាគមស្ត្រី (sororities) វត្តអារាម អារាមដូនជី (convents) ឬទីកន្លែងថែទាំលក្ខណៈគ្រួសារ (residential care facilities) ឡើយ ហើយក៏មិនរាប់បញ្ចូលទាំងការរស់នៅបែបពាណិជ្ជកម្ម ដូចជាផ្ទះសមាគមន៍ (boarding houses) សណ្ឋាគារ ឬផ្ទះសំណាក់នោះដែរ[1]។ ពាក្យថា "បុគ្គលិក" និង "និយោជិត" គឺសម្រាប់រាប់បញ្ចូលទាំងគ្រូបង្វឹក និយោជិត បុគ្គលិកជំនួយ អ្នកស្ម័គ្រចិត្ត កម្មសិក្សាការី (interns) និងសិក្ខាកាម (trainees) បញ្ញាវន្ត (scholars) និងបុគ្គលដទៃទៀតដែលបំពេញការងារនៅទីងកន្លែង ឬក៏សម្រាប់សកម្មភាពកីឡាកម្សាន្ត។ ពាក្យថា "អ្នកលេងកីឡា" "អ្នកចូលរួម" "សមាជិកគ្រួសារ" "ភ្ញៀវ" ឬ "អតិថិជន" គួរតែយល់ថាត្រូវរាប់បញ្ចូលសមាជិកនៃសាធារណជន និងមនុស្សផ្សេងទៀតដែលមិនមែនជាបុគ្គលិកឬនិយោជិត ដែលចំណាយពេលវេលានៅតាមអាជីវកម្មឬទីតាំងនោះដោយផ្ទាល់ ឬចូលរួមក្នុងសកម្មភាពផ្សេង។ ពាក្យថា "ទីតាំងអាជីវកម្ម" "ទីតាំង" និង "ទីកន្លែង" សំដៅលើអាគារ ឬបរិវេណដែលបានអនុញ្ញាតឱ្យរៀបចំសកម្មភាពផ្សេងៗ។ "LACDPH" ឬ "សុខភាពសាធារណៈ" គឺជានាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles។

## ការធ្វើផែនការគ្រប់គ្រងការប៉ះពាល់មុនពេលកំណត់អត្តសញ្ញាណជំងឺ COVID-19 ចំនួន 1 ករណី

- ❑ *ចាំបាច់៖* មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំងសម្រាប់ជំងឺ COVID-19 នៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ (ឬហៅថា "មន្ត្រីអនុវត្តច្បាប់") ជាបុគ្គលដែលទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តរាល់ដំណើរការសុវត្ថិភាពទាក់ទងនឹងជំងឺ COVID-19 និងធានាថាអ្នកចូលរួមទាំងអស់ទទួលបានការអប់រំណែនាំអំពីជំងឺ COVID-19។ មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំងសម្រាប់ជំងឺ COVID-19 នេះនឹងមានតួនាទីជាចំណុចទំនាក់ទំនងទៅ DPH សម្រាប់ការចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវនេះ។

- ❑ *ចាំបាច់៖* ផែនការសម្រាប់អ្នកចូលរួម និងបុគ្គលិកទាំងអស់ដែល (1) មានរោគសញ្ញាដូចនឹងជំងឺ COVID-19 (2) ត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក ដោយសារតែមានការប៉ះពាល់នឹងមេរោគ ឬ (3) គឺជាផ្នែកមួយនៃកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ហើយដែលមានការស៊ើបអង្កេតពីសុខភាពសាធារណៈយ៉ាងសកម្ម ឱ្យមានសិទ្ធិធ្វើតេស្ត ឬធ្វើតេស្តរកជំងឺ COVID-19។ *កំណត់សម្គាល់៖ បុគ្គលដែលគ្មានរោគសញ្ញា ហើយដែលបានចាក់ថ្នាំបង្ការពេញលេញ[2] ឬអ្នកដែលបានជាសះស្បើយពីជំងឺ COVID-19 ដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមកមិនចាំបាច់តម្រូវឱ្យធ្វើតេស្ត ឬធ្វើចត្តាឡីស័កទេ លើកលែងតែសុខភាពសាធារណៈយល់ថាវាជាការចាំបាច់សម្រាប់ជាផ្នែកមួយនៃការស៊ើបអង្កេតយ៉ាងសកម្ម។

- ❑ *ចាំបាច់៖* ផែនការមួយដែលតម្រូវឱ្យអត្តពលិកវ័យក្មេង (youth athletes) និងបុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការ ហើយដែលចូលរួមក្នុងកីឡាដែលប្រឈមនឹងកម្រិតហានិភ័យមធ្យមឬខ្ពស់ដែលប្រព្រឹត្តិទៅនៅខាងក្នុងអគារ និងអត្តពលិកវ័យក្មេងដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ និងបុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការ ហើយដែលចូលរួមក្នុងកីឡាដែលប្រឈមនឹងកម្រិតហានិភ័យមធ្យមឬខ្ពស់ដែលប្រព្រឹត្តិទៅនៅខាងក្រៅអគារ ធ្វើតេស្តរកមេរោគរៀងរាល់សប្តាហ៍។ លើសពីនេះទៀត ប្រសិនបើមានករណីឆ្លងជំងឺ COVID-19 ច្បាស់លាស់នៅក្នុងក្រុមកីឡាយុវជន អត្តពលិកនិងបុគ្គលិកដែលចូលរួមក្នុងក្រុមកីឡាយុវជននោះ តម្រូវឱ្យធ្វើតេស្តប្រចាំសប្តាហ៍រយៈពេល 2 សប្តាហ៍ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការ ឬប៉ះពាល់នឹងមេរោគឡើយ។ កំណត់សម្គាល់៖ ការធ្វើតេស្តពិនិត្យតាមដានប្រចាំសប្តាហ៍មិនតម្រូវចាំបាច់សម្រាប់ (1) បុគ្គលដែលបានចាក់ថ្នាំបង្ការពេញលេញ (2) បុគ្គលដែលបានជាសះស្បើយពីជំងឺ COVID-19 ហើយដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមក (3) អត្តពលិកដែលមានអាយុតិចជាង 12 ឆ្នាំ ហើយដែលបានចូលរួមក្នុងកីឡាដែលប្រឈមនឹងកម្រិតហានិភ័យទាប មធ្យម ឬខ្ពស់ទាំងអស់ដែលប្រព្រឹត្តិទៅនៅខាងក្រៅអគារ។ បញ្ជីរៀបរាប់ប្រភេទកីឡាដែលបែងចែកតាមកម្រិតហានិភ័យត្រូវបានផ្តល់ជូននៅក្នុង [ពិធីការសម្រាប់ក្រុមកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ]។

---

[1]លេខកូដខោនធី Los Angeles Title 22. §22.14.060 - F. និយមន័យគ្រួសារ (Ord. 2019-0004 § 1, 2019.)
https://library.municode.com/ca/los_angeles_county/codes/code_of_ordinances?nodeId=TIT22PLZO_DIV2DE_CH22.14DE_22.14.060F

[2] ការចាក់ថ្នាំបង្ការពេញលេញត្រូវបានកំណត់យ៉ាងច្បាស់ថា ពីរសប្តាហ៍ឡើងទៅបានកន្លងផុត ចាប់តាំងពីការទទួលបានដូសទីពីរនៃប្រភេទថ្នាំបង្ការដែលមានលំដាប់ 2 ដូស ឬពីរសប្តាហ៍ឡើងទៅបានកន្លងផុត ចាប់តាំងពីចាក់ថ្នាំបង្ការដែលមានតែមួយដូសរួចរាល់មក។

- ❑ *បានណែនាំ៖* ក្នុងអំឡុងពេលនៃការប្រកួតរវាងខោនធីជាច្រើន ហើយមានរយៈពេលច្រើនថ្ងៃ បានណែនាំឱ្យអត្តពលិក និងបុគ្គលិកដែលចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះធ្វើតេស្តជំងឺ COVID-19 ទទួលលទ្ធផលអវិជ្ជមានក្នុងអំឡុងពេល 3 ថ្ងៃមុនការប្រកួតដំបូង។
- ❑ *បានណែនាំ៖* កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវដែលជ្រើសរើសអនុវត្តកម្មវិធីពិនិត្យរករោគសញ្ញាត្រូវបានផ្តល់ដំបូន្មានឲ្យអនុវត្តតាមសេចក្តីណែនាំរបស់ DPH ស្តីពី វិធីសាស្ត្រសម្រេចចិត្ត សម្រាប់បុគ្គលទាំងឡាយដែលមិនបានធ្វើតេស្តរកមេរោគ COVID-19 ប៉ុន្តែពិនិត្យឃើញវិជ្ជមានសម្រាប់រោគសញ្ញាមុន ឬអំឡុងពេលចូលរួមក្នុងកម្មវិធីកីឡានោះ។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ជំងឺ COVID-19 ចំនួន 1 ករណី

- ❑ *ចាំបាច់៖* បន្ទាប់ពីកំណត់អត្តសញ្ញាណករណីជំងឺ COVID-19 ច្បាស់លាស់ចំនួន 1 (អ្នកចូលរួម ឬបុគ្គលិក) មន្ត្រីអនុវត្តច្បាប់បង្គាប់ឱ្យករណីនេះអនុវត្តតាមសេចក្តីណែនាំអំពីការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះសម្រាប់ជំងឺ COVID-19 (ph.lacounty.gov/covidisolation)។ កំណត់សម្គាល់៖ ក្នុងករណីជំងឺ COVID-19 ច្បាស់លាស់ គឺជាបុគ្គលដែលបានធ្វើតេស្តជំងឺ COVID-19 ទទួលលទ្ធផលវិជ្ជមាន។
- ❑ *ចាំបាច់៖* មន្ត្រីអនុវត្តច្បាប់ផ្តល់ច្បាប់ចម្លងនៃ សេចក្តីបង្គាប់ឱ្យដាក់នៅដាច់ដោយឡែក ជាបន្ទាប់របស់សុខភាពសាធារណៈទៅ ហើយជូនដំណឹងករណីនេះថា DPH នឹងទាក់ទងទៅករណីនេះដោយផ្ទាល់តាមរយៈកម្មវិធីស៊ើបអង្កេតករណីនិងទំនាក់ទំនងរបស់ DPH (DPH Case and Contact Investigation Program) ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលជូនសម្រាប់ករណីដាក់ឱ្យនៅដាច់ដោយឡែកនេះជាផ្លូវការ។
- ❑ *ចាំបាច់៖* មន្ត្រីអនុវត្តច្បាប់ធ្វើការដើម្បីកំណត់អត្តសញ្ញាណបុគ្គលទាំងអស់នៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវនេះ ដែលមានការប៉ះពាល់នឹងករណីវិជ្ជមានច្បាស់លាស់ក្នុងអំឡុងពេលដែលពួកគេអាចចម្លងមេរោគបាន (បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ)។
  - ករណីមួយត្រូវបានចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃមុនកាលបរិច្ឆេទ (ថ្ងៃខែ) ចាប់ផ្តើមមានរោគសញ្ញារបស់ពួកគេ រហូតដល់ពេលដែលពួកគេលែងតម្រូវឱ្យនៅដាច់ដោយឡែកពីគេ (ពោលគឺ មិនមានអការៈគ្រុនក្តៅយ៉ាងហោចណាស់ 24 ម៉ោង ដោយមិនប្រើប្រាស់ថ្នាំបញ្ចុះកម្តៅ ហើយរោគសញ្ញាផ្សេងៗបានធូរស្បើយ និងយ៉ាងហោចណាស់ 10 ថ្ងៃបានកន្លងផុតទៅចាប់តាំងពីកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ)។ មនុស្សដែលបានធ្វើតេស្តជំងឺ COVID-19 ទទួលលទ្ធផលវិជ្ជមាន ប៉ុន្តែមិនមានរោគសញ្ញា ត្រូវបានចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃមុនពេលពួកគេធ្វើតេស្តរហូតដល់ 10 ថ្ងៃបន្ទាប់ពីការធ្វើតេស្តរបស់ពួកគេ។
  - បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ៖ បុគ្គលម្នាក់ត្រូវបានចាត់ទុកថាបានប៉ះពាល់នឹងករណីមួយក្នុងអំឡុងពេលដែលអាចចម្លងមេរោគបាន ប្រសិនបើត្រូវតាមចំណុចយ៉ាងហោចណាស់មួយក្នុងចំណោមល័ក្ខខ័ណ្ឌខាងក្រោម៖
    - ស្ថិតនៅក្នុងបរិវេណ 6 ហ្វីតពីមនុស្សដែលផ្ទុកជំងឺ រយៈពេលសរុប 15 នាទីឬយូរជាងនេះក្នុងអំឡុងពេល 24 ម៉ោង។
    - មានការប៉ះពាល់ជាមួយនឹងសារធាតុរាវក្នុងខ្លួនរបស់មនុស្សដែលផ្ទុកមេរោគ និង/ឬសារធាតុបញ្ចេញផ្សេងៗរបស់មនុស្សដែលមានជំងឺ COVID-19 ច្បាស់លាស់ដោយមិនបានការពារ (ឧទាហរណ៍ ត្រូវបានក្អកឬកណ្តាស់ដាក់ ប្រើប្រាស់ប្រដាប់ប្រដាបរិភោគអាហាររួមគ្នាឬដាប់ទឹកមាត់គ្នា ឬផ្តល់ការថែទាំដោយមិនប្រើឧបករណ៍ការពារត្រឹមត្រូវ)។
    - ការប៉ះពាល់ទាំងឡាយនឹងត្រូវបានពិនិត្យឡើងវិញដោយសុខភាពសាធារណៈដើម្បីបញ្ជាក់ថា តើបុគ្គលណាខ្លះចាំបាច់ត្រូវតែធ្វើចត្តាឡីស័ក ក្នុងនេះរួមទាំងអាចមានការធ្វើចត្តាឡីស័កចំពោះបុគ្គលទាំងអស់ដែលស្ថិតនៅក្នុងក្រុមតែមួយជាមួយនឹងមនុស្សដែលផ្ទុកមេរោគ ឬបុគ្គលនៅក្នុងក្រុមគូប្រកួតដែលបានប្រកួតនឹងក្រុមដែលមានអ្នកផ្ទុកមេរោគ ប្រសិនបើមិនអាចបែងចែកការប៉ះពាល់នោះបានទេ។
- ❑ *ចាំបាច់៖* មន្ត្រីអនុវត្តច្បាប់ត្រូវរាយការណ៍ចំណុចដូចតទៅនេះទៅកាន់សុខភាពសាធារណៈ៖ (1) បុគ្គលិក និងអ្នកចូលរួមដែលមានជំងឺ COVID-19 ច្បាស់លាស់ ហើយដែលបានចូលរួមក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវនៅពេលណាមួយក្នុងអំឡុងពេល 14 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ និង (2) បុគ្គលទាំងឡាយដែលនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ដែលត្រូវបានប៉ះពាល់ជាមួយអ្នកផ្ទុកមេរោគក្នុងអំឡុងពេលអាចចម្លងមេរោគបាន។

- ការរាយការណ៍តាមអនឡាញដែលមានសុវត្ថិភាពគឺជាវិធីសាស្ត្រដ៏ល្អសម្រាប់ជូនដំណឹងទៅ DPH អំពីមានការប៉ះពាល់នឹងជំងឺ COVID-19 ហើយអាចធ្វើនៅលើកុំព្យូទ័រ ឬឧបករណ៍ចល័តដែលអាចចូលទៅកាន់គេហទំព័រដែលមានសុវត្ថិភាពតាមរយៈ៖ http://www.redcap.link/lacdph.educationsector.covidreport។ ប្រសិនបើការរាយការណ៍តាមអនឡាញមិនអាចធ្វើទៅបានទេនោះ ការរាយការណ៍អាចធ្វើឡើងដោយផ្ទាល់តាមរយៈការទាញយក និងបំពេញ តារាងបញ្ជីករណីនិងអ្នកដែលទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើទៅអាសយដ្ឋានអ៊ីម៉េលនេះ ACDC-Education@ph.lacounty.gov។ រាល់ការជូនដំណឹងអំពីករណីទាំងអស់គួរតែត្រូវបានដាក់បញ្ជូនក្នុងចន្លោះពេល 1 ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងអំពីករណីនេះ។

❑ *ចាំបាច់៖* ប្រសិនបើបុគ្គលដែលបានប៉ះពាល់ជាមួយនឹងជំងឺត្រូវបានកំណត់អត្តសញ្ញាណថាមកក្រុមគូប្រកួត នោះមន្ត្រីអនុវត្តច្បាប់របស់ក្រុមគូប្រកួតនោះត្រូវតែរាយការណ៍អំពីបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធទៅដល់ DPH តាមរយៈអ៊ីមែល ACDC-Education@ph.lacounty.gov។ DPH នឹងសហការជាមួយមន្ត្រីអនុវត្តច្បាប់នោះដើម្បីប្រមូលព័ត៌មានដែលចាំបាច់ស្តីពីការប៉ះពាល់ រួមទាំងព្រឹត្តិការណ៍កីឡាជាក់លាក់ដែលការប៉ះពាល់នឹងមេរោគបានកើតឡើង និងព័ត៌មានបន្ថែមលើបុគ្គលទាំងឡាយដែលបានប៉ះពាល់នឹងមេរោគដើម្បីបញ្ជាក់ថា តើបុគ្គលណាខ្លះដែលតម្រូវឱ្យធ្វើចត្តាឡីស័ក។

❑ *ចាំបាច់៖* មនុស្សទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណថាមានការប៉ះពាល់ទៅនឹងករណីជំងឺ COVID-19 ដែលវិជ្ជមាននៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ត្រូវបានជូនដំណឹងដោយមន្ត្រីអនុវត្តច្បាប់អំពីការប៉ះពាល់នេះ។ ការប្រាស្រ័យទាក់ទងគួរតែត្រូវបានភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃ សេចក្តីបង្គាប់ឱ្យធ្វើចត្តាឡីស័ក ជាបន្ទាន់របស់សុខភាពសាធារណៈ។ ការជូនដំណឹងអំពីការប៉ះពាល់គួរតែរួមបញ្ចូលកត្តាដូចដែលរៀបរាប់ខាងក្រោម។ កំណត់សម្គាល់៖ គំរូលិខិតជូនដំណឹងអំពីការប៉ះពាល់អាចរកបានតាមរយៈ គំរូលិខិតជូនដំណឹងសម្រាប់កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវសម្រាប់ជំងឺ COVID-19 (សូមមើលគំរូលិខិតលេខ 1)។

- អ្នកចូលរួម និងបុគ្គលិកដែលមានការប៉ះពាល់* ទៅនឹងករណី គួរតែធ្វើតេស្តរកមេរោគ COVID-19 ទោះបីជាពួកគេមានឬគ្មានរោគសញ្ញា ហើយជូនដំណឹងដល់មន្ត្រីអនុវត្តច្បាប់អំពីលទ្ធផលនៃការធ្វើតេស្តនេះ។ នេះនឹងកំណត់កម្រិតនៃការរីករាលដាលនៃជំងឺនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ហើយនឹងក្លាយជាមូលដ្ឋានសម្រាប់វិធានការណ៍ត្រួតពិនិត្យផ្សេងៗបន្ថែមទៀត។ ធនធានសម្រាប់ធ្វើតេស្តរួមមាន៖ សេវាកម្មសុខភាពបុគ្គលិក ឬសេវាកម្មសុខភាពការងារ មណ្ឌលសុខភាពសម្រាប់សិស្សនិស្សិត អ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្ទាល់ខ្លួន ទីតាំងធ្វើតេស្តតាមរបស់ក្រុងនិងខោនធី LA ដែលអាចរកបាននៅ៖ covid19.lacounty.gov/testing និងនៅ ទីតាំងធ្វើតេស្តតាមសហគមន៍ (មណ្ឌលសុខភាព និងឱសថស្ថានក្នុងតំបន់)។ បុគ្គលទាំងឡាយដែលត្រូវការជំនួយក្នុងការស្វែងរកអ្នកផ្តល់សេវាវេជ្ជសាស្ត្រ អាចទូរស័ព្ទទៅបណ្តាញព័ត៌មានខោនធី LA តាមរយៈលេខ 2-1-1 ដែលបម្រើការជូន 24 ម៉ោងក្នុងមួយសប្តាហ៍។
- មនុស្សដែលបានប៉ះពាល់នឹងមេរោគ ហើយដែលមិនត្រូវបានលើកលែងពីការធ្វើចត្តាឡីស័ក (សូមមើលការលើកលែងខាងក្រោម) ត្រូវតែធ្វើចត្តាឡីស័កដោយខ្លួនឯង* (ស្នាក់នៅតែផ្ទះរបស់ពួកគេ ឬលំនៅដ្ឋានមួយផ្សេងទៀត និងនៅឆ្ងាយពីអ្នកដទៃ) និងតាមដានរោគសញ្ញាដូចមានចែងនៅក្នុង សេចក្តីណែនាំអំពីកាធ្វើចត្តាឡីស័ក និងសេចក្តីណែនាំសម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ។ ដរាបណាពួកគេមិនកើតមានរោគសញ្ញានៃជំងឺ COVID-19 ពួកគេអាចបញ្ចប់ពីការធ្វើចត្តាឡីស័កនៅ៖
- បន្ទាប់ពី 10 ថ្ងៃពេញបានកន្លងផុតទៅ បន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់ពួកគេចំពោះករណីដែលអាចចម្លងមេរោគបាន (ដូចបានកំណត់ខាងលើ)។ សកម្មភាពផ្សេងៗអាចបន្តចាប់ផ្តើមនៅថ្ងៃទី 11។ ពួកគេត្រូវតែបន្តតាមដានសុខភាពរបស់ពួកគេ និងប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នក្នុងការបង្ការជំងឺ COVID-19 រហូតដល់ថ្ងៃទី 14 ។
- បន្ទាប់ពី 7 ថ្ងៃពេញបានកន្លងផុតទៅ បន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់ពួកគេចំពោះករណីដែលអាចចម្លងមេរោគបាន ប្រសិនបើពួកគេទទួលលទ្ធផលធ្វើតេស្តរកមេរោគអវិជ្ជមាន ពីសំណាកដែលប្រមូលបាននៅថ្ងៃទី 5 ឬក្រោយមកទៀត បន្ទាប់ពីកាលបរិច្ឆេទនៃការប៉ះពាល់ចុងក្រោយទៅនឹងករណីនេះ។ សកម្មភាពអាចបន្តចាប់ផ្តើមនៅថ្ងៃទី 8។ ពួកគេត្រូវតែបន្តតាមដានសុខភាពរបស់ពួកគេ និងប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នក្នុងការបង្ការជំងឺ COVID-19 រហូតដល់ថ្ងៃទី 14។ សូមកត់សម្គាល់ថា ការធ្វើតេស្តនេះត្រូវតែជាការធ្វើតេស្តជំងឺ COVID-19 ដែលទទួលស្គាល់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) រួមមានទាំងការធ្វើតេស្តរកហ្សែនមេរោគ ឬការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ីច [(NAAT) ដូចជាតេស្តរកទម្រង់មេរោគ (PCR)] ឬតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (Antigen test) ដែលសំណាកត្រូវបានប្រមូល និងធ្វើតេស្តឡើងនៅក្នុងកន្លែងថែទាំសុខភាព ឬកន្លែងធ្វើតេស្តដែលមានការទទួលស្គាល់ត្រឹមត្រូវ។
- បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធដូចខាងក្រោមត្រូវបានលើកលែងពីការធ្វើចត្តាឡីស័ក ប្រសិនបើពួកគេនៅតែមិនមានចេញរោគសញ្ញា៖

- មនុស្សដែលបានចាក់ថ្នាំបង្ការពេញលេញ។
- បុគ្គលដែលបានជាសះស្បើយពីជំងឺ COVID-19 ហើយដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមក។

ទោះបីជាពួកគេមិនចាំបាច់ធ្វើចត្តាឡីស័កក៏ដោយ ពួកគេត្រូវតែតាមដានរោគសញ្ញានានា ហើយប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនូវការប្រុងប្រយ័ត្នចំពោះជំងឺ COVID-19 រយៈពេល 14 ថ្ងៃចាប់ពីថ្ងៃនៃការប៉ះពាល់ចុងក្រោយរបស់ពួកគេ។ មានការណែនាំឱ្យអ្នកដែលបានចាក់ថ្នាំបង្ការពេញលេញ ធ្វើតេស្តរកមេរោគអំឡុងពេល 3 ទៅ 5 ថ្ងៃបន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់ពួកគេ។ ការធ្វើតេស្តមិនត្រូវបានណែនាំសម្រាប់អ្នកដែលទើបតែជាសះស្បើយពីជំងឺ COVID-19 នោះទេ។ សូមមើល សេចក្តីណែនាំអំពីការធ្វើចត្តាឡីស័ក និងសេចក្តីណែនាំសម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ។

- DPH នឹងទាក់ទងមនុស្សដែលបានប៉ះពាល់នឹងជំងឺ ដែលស្របទៅនឹងតម្រូវការឱ្យធ្វើចត្តាឡីស័កតាមរយៈកម្មវិធីស៊ើបអង្កេតករណីនិងទំនាក់ទំនងរបស់ DPH ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលជូនសម្រាប់ឱ្យធ្វើចត្តាឡីស័កជាផ្លូវការ។

❑ ចាំបាច់៖ គ្រប់សមាជិកក្រុមទាំងអស់ដែលចូលរួមនៅក្នុងក្រុមតែមួយជាមួយនឹងករណីដែលមានជំងឺច្បាស់លាស់ គឺតម្រូវឱ្យធ្វើតេស្តជារៀងរាល់សប្តាហ៍រយៈពេល 2 សប្តាហ៍ គិតចាប់ពីថ្ងៃចុងក្រោយដែលករណីនោះមានវត្តមានក្នុងក្រុមខណៈពេលដែលអាចចម្លងមេរោគបាន ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការ ឬប៉ះពាល់នឹងមេរោគឡើយ។

❑ *ចាំបាច់៖* ប្រសិនបើបុគ្គលដែលមានជំងឺ COVID-19 ច្បាស់លាស់បានចូលរួមនៅក្នុងការលេងកីឡាណាមួយ ការប្រកួតប្រជែង ឬក៏សកម្មភាពដែលទាក់ទងនឹងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងក្រុមដទៃទៀតក្នុងអំឡុងពេលអាចចម្លងមេរោគរបស់ពួកគេបាន មន្ត្រីអនុវត្តច្បាប់ត្រូវតែជូនដំណឹងដល់ក្រុមគូប្រកួតមួយ (ឬច្រើន) អំពីការប៉ះពាល់ដែលអាចកើតមានឡើង។ គំរូលិខិតជូនដំណឹងអំពីការប៉ះពាល់អាចរកបានតាមរយៈ គំរូលិខិតជូនដំណឹងសម្រាប់កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវសម្រាប់ជំងឺ COVID-19 (សូមមើលគំរូលិខិតលេខ 2)។ មន្ត្រីអនុវត្តច្បាប់សម្រាប់ក្រុមដែលរងផលប៉ះពាល់ទាំងអស់ត្រូវតែធ្វើការសហការដើម្បីកំណត់អត្តសញ្ញាណបុគ្គលណាដែលស្របតាមលក្ខខ័ណ្ឌចំពោះការប៉ះពាល់នឹងមេរោគ។ ប្រសិនបើក្រុមគូប្រកួតមានបុគ្គលណាដែលបានប៉ះពាល់នឹងមេរោគនោះ មន្ត្រីអនុវត្តច្បាប់របស់ក្រុមគូប្រកួតនោះត្រូវតែជូនដំណឹងទៅ DPH អំពីការប៉ះពាល់នេះដោយអ៊ីម៉ែលទៅ ACDC-Education@ph.lacounty.gov ក្នុងចន្លោះពេល 1 ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងអំពីការប៉ះពាល់នឹងមេរោគនោះ។ DPH នឹងសហការជាមួយមន្ត្រីអនុវត្តច្បាប់របស់ក្រុមគូប្រកួតដើម្បីប្រមូលព័ត៌មានចាំបាច់សម្រាប់ការគ្រប់គ្រងការប៉ះពាល់។

❑ *បានណែនាំ៖* មន្ត្រីអនុវត្តច្បាប់នឹងកំណត់ថា តើចាំបាច់ត្រូវធ្វើការជូនដំណឹងបន្ថែមដែរឬទេ ដល់សហគមន៍កម្មវិធីដែលទូលំទូលាយអំពីការប៉ះពាល់ និងការប្រុងប្រយ័ត្នដែលកំពុងត្រូវបានអនុវត្ត ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19។ គំរូលិខិតជូនដំណឹងអំពីការប៉ះពាល់ទូទៅអាចរកបានតាមរយៈ៖ គំរូលិខិតជូនដំណឹងសម្រាប់កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវសម្រាប់ជំងឺ COVID-19 (សូមមើលលិខិតគំរូលេខ 3)។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ជំងឺ COVID-19 ចំនួន 2 ករណី ក្នុងអំឡុងពេល 14 ថ្ងៃ

❑ *ចាំបាច់៖* បន្ទាប់ពីកំណត់អត្តសញ្ញាណ ច្បាស់លាស់ចំនួន 2 ករណី (អ្នកចូលរួម និងបុគ្គលិក) ក្នុងអំឡុងពេល 14 ថ្ងៃ កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវអនុវត្តតាមជំហានដែល *ចាំបាច់* សម្រាប់ករណីច្បាស់លាស់ ចំនួន 1 ។

❑ *បានណែនាំ៖* មន្ត្រីអនុវត្តច្បាប់កំណត់ថាតើ ករណីទាំង 2 ទាក់ទងនឹងការរីករាលដាលនៃជំងឺដែរឬទេ នេះគឺមានន័យថាបុគ្គលដែលរងផលប៉ះពាល់ទាំងពីរនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ គឺមានវត្តមាននៅចំណុចណាមួយក្នុងទីកន្លែងដូចគ្នា ក្នុងរយៈពេលតែមួយ ខណៈពេលដែលភាគីតែម្ខាង ឬទាំងពីរអាចចម្លងមេរោគបាន។

- ការកំណត់ពីការទាក់ទងនឹងការរីករាលដាលនៃជំងឺរវាងករណីជាច្រើនអាចតម្រូវឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ដើម្បីវាយតម្លៃលើប្រវត្តិប៉ះពាល់នឹងមេរោគ និងកំណត់ទីកន្លែងនិងបុគ្គលដែលអាចមានទាំងអស់ហើយដែលអាចត្រូវបានប៉ះពាល់ជាមួយករណី ខណៈពេលកំពុងអាចចម្លងមេរោគនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវនេះ។ ចំណាំ៖ ករណីដែលទាក់ទងនឹងការរីករាលដាលនៃជំងឺ រួមមានបុគ្គលដែលនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ហើយដែលមានទំនាក់ទំនងជាមួយអ្នកដទៃដែលអាចកំណត់អត្តសញ្ញាណបាន (ឧទាហរណ៍ នៅក្រុមតែមួយ នៅក្នុងបរិវេណដែលប្រើរួមគ្នាដូចជាបន្ទប់ដាក់សម្ភារៈឬក្នុងឡាន ចូលរួមការជួបជុំសង្គមជាមួយគ្នា) ចង្អុលបង្ហាញពីលទ្ធភាពខ្ពស់នៃការរីករាលដាលនៃជំងឺនៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ជាជាងការឆ្លងមេរោគម្តងម្កាលពីសហគមន៍ទូទៅ។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ជំងឺ COVID-19 ចំនួន ≥ 3 ករណី ក្នុងអំឡុងពេល 14 ថ្ងៃ

❑ *ចាំបាច់៖* ប្រសិនបើកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ កំណត់អត្តសញ្ញាណនៃករណីឆ្លងជាចង្កោមច្បាស់លាស់ចំនួន 3 ឡើងទៅ (អ្នកចូលរួម និង/ឬបុគ្គលិក) ក្នុងអំឡុងពេល 14 ថ្ងៃជាប់គ្នា កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ គួរតែអនុវត្តតាមជំហានដូចខាងក្រោម៖

- រាយការណ៍ការឆ្លងជាចង្កោមទៅ DPH ជាបន្ទាន់។ ការរាយការណ៍តាមអនឡាញដែលមានសុវត្ថិភាពគឺជាវិធីសាស្ត្រដ៏ល្អសម្រាប់ការជូនដំណឹងទៅ DPH ហើយអាចធ្វើនៅលើកុំព្យូទ័រ ឬឧបករណ៍ចល័តដែលអាចចូលទៅកាន់គេហទំព័រដែលមានសុវត្ថិភាពតាមរយៈ៖ http://www.redcap.link/lacdph.educationsector.covidreport។ ប្រសិនបើការរាយការណ៍តាមអនឡាញមិនអាចធ្វើទៅបានទេ ការរាយការណ៍អាចធ្វើដោយផ្ទាល់តាមរយៈការទាញយក និងបំពេញ តារាងបញ្ជីករណីនិងអ្នកដែលទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើទៅអាសយដ្ឋានអ៊ីម៉ែលនេះ៖ ACDC-Education@ph.lacounty.gov។

- DPH នឹងពិនិត្យមើលឡើងវិញនូវព័ត៌មានដែលបានបញ្ជូនទៅដើម្បីកំណត់ថា តើបានស្របតាមល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺដែលបានពិពណ៌នាខាងក្រោមដែរឬទេ ហើយនឹងជូនដំណឹងដល់កម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវក្នុងចន្លោះពេល 1 ថ្ងៃអំពីជំហានបន្តបន្ទាប់។

- ល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺសម្រាប់វិស័យអប់រំ៖ យ៉ាងហោចណាស់មានករណីច្បាស់លាស់ចំនួន 3 ដែលមានឬគ្មានរោគសញ្ញានៃជំងឺ COVID-19 ក្នុងអំឡុងពេល 14 ថ្ងៃជាប់គ្នា ក្នុងចំណោមសមាជិកនៃកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ ដែលទាក់ទងនឹងការរីករាលដាលនៃជំងឺ មិនស្នាក់នៅក្នុងគ្រួសារតែមួយ និងមិនមែនជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធរវាងគ្នាទៅវិញទៅមកនៅក្រៅទីតាំងនៃវិស័យអប់រំ ឬកម្មវិធីយុវជន។ ទំនាក់ទំនងនឹងការរីករាលដាលនៃជំងឺតម្រូវឱ្យអ្នកដែលផ្ទុកមេរោគមានវត្តមាននៅចំណុចណាមួយក្នុងទីកន្លែងដូចគ្នា ក្នុងរយៈពេលតែមួយ ខណៈពេលដែលអាចចម្លងមេរោគបាន។
  - ប្រសិនបើស្របតាមល័ក្ខខ័ណ្ឌនៃការផ្ទុះមេរោគនេះ DPH នឹងជូនដំណឹងដល់មន្ត្រីអនុវត្តច្បាប់ថា ការស៊ើបអង្កេតអំពីការផ្ទុះជំងឺត្រូវបានដាក់ឱ្យដំណើរការសម្រាប់កម្មវិធីកីឡាយុវជននោះ។ អ្នកស៊ើបអង្កេតសុខភាពសាធារណៈនឹងទាក់ទងដោយផ្ទាល់ជាមួយមន្ត្រីអនុវត្តច្បាប់ ដើម្បីសម្របសម្រួលការឆ្លើយតបការផ្ទុះឡើងនេះ។ កម្មវិធីកីឡាយុវជនប្រហែលជាអាចត្រូវបានតម្រូវឱ្យផ្អាកសកម្មភាពនានាសម្រាប់ក្រុមកីឡា ឬពួកអ្នកលេងកីឡាដែលមានការផ្ទុះជំងឺនេះ រហូតដល់មានការជូនដំណឹងបន្ថែមទៀត។ ការដាក់បញ្ជូននូវលទ្ធផលវិជ្ជមានមិនពិតពីកម្មវិធីកីឡាយុវជនដែលមានការផ្ទុះជំងឺយ៉ាងសកម្មនេះ នឹងមិនទទួលយកទេក្នុងអំឡុងពេលនៃការស៊ើបអង្កេតការផ្ទុះជំងឺនេះ។

## ឧបសម្ព័ន្ធ A៖ ជំហានសម្រាប់ការគ្រប់គ្រងការប៉ះពាល់នឹងករណីជំងឺ COVID-19 នៅក្នុងកម្មវិធីកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវមួយ

| | |
|---|---|
| **1 ករណី** | 1) *ចាំបាច់៖* កម្មវិធីកីឡាយុវជនបង្គាប់ករណីឱ្យអនុវត្តតាមសេចក្តីណែនាំអំពី ការឱ្យដាក់នៅដាច់ដោយឡែក នៅផ្ទះសម្រាប់ជំងឺ COVID-19។<br>2) *ចាំបាច់៖* កម្មវិធីកីឡាយុវជនផ្តល់ជូននូវច្បាប់ចម្លងនៃសេចក្តីបង្គាប់ការឱ្យដាក់នៅដាច់ដោយឡែកជាបន្ទាន់របស់សុខភាពសាធារណៈ និងជូនដំណឹងដល់ករណីនេះថា DPH នឹងទាក់ទងទៅករណីនេះដោយផ្ទាល់ដើម្បីប្រមូលព័ត៌មានបន្ថែម របស់សុខភាពសាធារណៈជូនជាផ្លូវការ។<br>3) *ចាំបាច់៖* កម្មវិធីកីឡាយុវជនសហការជាមួយករណីដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលបានប៉ះពាល់ជាមួយនឹងករណីនេះ។ នេះអាចរាប់បញ្ចូលបុគ្គលទាំងអស់ឡាយនៅក្នុងក្រុមគូប្រកួត ប្រសិនបើករណីនេះបានចូលរួមក្នុងការលេង ឬការប្រកួតណាមួយក្នុងអំឡុងពេលអាចចម្លងមេរោគរបស់ពួកគេបាន។ កំណត់សម្គាល់៖ DPH នឹងសហការជាមួយកម្មវិធីកីឡាមួយ (ឬច្រើន) ដើម្បីបញ្ជាក់ពីករណីដែលមានការប៉ះពាល់នឹងមេរោគទាំងអស់ ដែលចាំបាច់ត្រូវតែធ្វើចត្តាឡីស័ក រួមទាំងប្រហែលជាអាចឱ្យមនុស្សទាំងអស់ដែលមិនត្រូវបានកំណត់ឈ្មោះពីដំបូងថាបានប៉ះពាល់ជិតស្និទ្ធនៅក្នុងកម្មវិធីកីឡាយុវជន ធ្វើចត្តាឡីស័កដែរ ប្រសិនបើមិនអាចបែងចែកការប៉ះពាល់នឹងមេរោគបាន។<br>4) *ចាំបាច់៖* កម្មវិធីកីឡាយុវជនជូនដំណឹង* ដល់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធអំពីការប៉ះពាល់នឹងមេរោគ។ បុគ្គលដែលមានទំនាក់ទំនងទាំងនោះត្រូវបានណែនាំឱ្យធ្វើចត្តាឡីស័កនៅផ្ទះ ធ្វើតេស្តរកមេរោគ COVID-19 ដោយសារការប៉ះពាល់របស់ពួកគេ និងផ្តល់ជូននូវច្បាប់ចម្លងនៃ សេចក្តីបង្គាប់ការធ្វើចត្តាឡីស័ក បន្ទាន់របស់សុខភាពសាធារណៈ។ ពួកគេត្រូវបានជូនដំណឹងថា DPH នឹងទាក់ទងទៅពួកគេដោយផ្ទាល់ដើម្បីប្រមូលព័ត៌មានបន្ថែម។<br>5) *ចាំបាច់៖* កម្មវិធីកីឡាយុវជនបញ្ជូនរបាយការណ៍ទៅ DPH ក្នុងចន្លោះពេល 1 ថ្ងៃធ្វើការ ដោយមានព័ត៌មានអំពីករណីច្បាស់លាស់ និងមនុស្សដែលបានប៉ះពាល់នឹងករណីនេះនៅក្នុងកម្មវិធីកីឡាយុវជន។<br>6) *បានណែនាំ៖* កម្មវិធីកីឡាយុវជនត្រូវផ្ញើសេចក្តីជូនដំណឹងទូទៅ* ដើម្បីជូនដំណឹងដល់សហគមន៍ដែលទូលំទូលាយអំពីការប៉ះពាល់ និងការប្រុងប្រយ័ត្នដែលបានធ្វើឡើងដើម្បីទប់ស្កាត់ការរីករាលដាល។ |
| **2 ករណី** | 1) *ចាំបាច់៖* អនុវត្តតាមជំហានដែលចាំបាច់សម្រាប់ករណីច្បាស់លាស់ចំនួន 1។<br>2) *ចាំបាច់៖* ប្រសិនបើករណីចំនួន 2 កើតឡើងក្នុងចន្លោះពេល 14 ថ្ងៃពីគ្នា កម្មវិធីកីឡាយុវជនសហការជាមួយ DPH ដើម្បីកំណត់ថា តើករណីទាំងនោះមានការទាក់ទងនឹងការរីករាលដាលជំងឺឬទេ។ ប្រសិនបើមានការទាក់ទងនឹងការរីករាលដាលជំងឺមែន កម្មវិធីកីឡាយុវជនត្រូវអនុវត្តវិធានការណ៍បន្ថែមក្នុងការគ្រប់គ្រងការចម្លងមេរោគ។ |
| **3+ ករណី** | 1) *ចាំបាច់៖* ប្រសិនបើករណីចម្លងជាចង្កោមមានចំនួន 3 ឡើងទៅកើតឡើងក្នុងចន្លោះពេល 14 ថ្ងៃពីគ្នា កម្មវិធីកីឡាយុវជនត្រូវជូនដំណឹងទៅដល់ DPH ជាបន្ទាន់។<br>2) *ចាំបាច់៖* DPH កំណត់ថា តើស្របនឹងល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺឬទេ។ ប្រសិនបើស្របតាមល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺមែន ការស៊ើបអង្កេតនៃការផ្ទុះជំងឺរបស់ DPH នឹងត្រូវបានដាក់ឱ្យដំណើរការ ហើយមន្ត្រីស៊ើបអង្កេតសុខភាពសាធារណៈនឹងទាក់ទងទៅកាន់កម្មវិធីកីឡាយុវជនដើម្បីសម្របសម្រួលការស៊ើបអង្កេតនៃការផ្ទុះជំងឺនោះ។ |